ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

**សេចក្តីប្រកាសព័ត៌មាន**
**ស្តីពី**
**ការដាក់ឱ្យដំណើរការគេហទំព័រធនធានអប់រំកម្ពុជា** (OER Cambodia)

ក្រសួងអប់រំ យុវជន និងកីឡាសូមជម្រាបជូន គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា បុគ្គលិកអប់រំ សិស្ស-និស្សិត និងសាធារណជនទាំងអស់ ជ្រាបថា៖ ក្រសួងនឹងដាក់ឱ្យដំណើរការគេហទំព័រធនធានអប់រំកម្ពុជា OER Cambodia ដែលមានតំណ oer.moeys.gov.kh ជាផ្លូវការចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ សម្រាប់គាំទ្រដល់ការបង្រៀននិងរៀន ស្របទៅតាមបរិបទនៃការអប់រំតាមបែបឌីជីថល និងបដិវត្តឧស្សាហកម្ម៤.០ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

គេហទំព័រធនធានអប់រំកម្ពុជា បានអភិវឌ្ឍឡើងក្នុងគោលបំណងលើកកម្ពស់ ជំរុញការចែករំលែក និងប្រើប្រាស់មាតិកាអប់រំឌីជីថល ឱ្យកាន់តែសម្បូរបែប សម្រាប់បម្រើដល់ការបង្រៀននិងរៀន តាមរយៈការអប់រំតាមបែបគន្លងថ្មី ក្នុងការចាប់យក និងពង្រឹងការប្រើប្រាស់បច្ចេកវិទ្យាឱ្យកាន់តែទូលំទូលាយ ជាពិសេសការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ក្នុងការធ្វើបរិវត្តកម្មឌីជីថលក្នុងប្រព័ន្ធអប់រំ ស្របពេលដែលស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩ នៅតែបន្ត។ លើសពីនេះ គេហទំព័រនេះ ផ្តល់ភាពងាយស្រួលដល់លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត អ្នកស្រាវជ្រាវ ក៏ដូចជាសាធារណជនទូទៅ ក្នុងការស្វែងរកឯកសារឌីជីថល តាមកម្រិតថ្នាក់ ចាប់ពីមត្តេយ្យសិក្សារហូតដល់កម្រិតឧត្តមសិក្សា តាមប្រភេទក្រុមមុខវិជ្ជា និងអាចស្វែងរកតាមប្រភេទនៃឯកសារដូចជា ពហុមេឌៀអន្តរកម្ម បទបង្ហាញ វីដេអូ នឹងសំឡេង ឯកសារបង្រៀននិងសៀវភៅណែនាំ កិច្ចតែងការបង្រៀន រូបភាពផ្ទាំងធំ និងរូបភាពគំនូរជីវចលអប់រំ ល្បែងសិក្សា និងឯកសារស្រាវជ្រាវនានា។

ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តដល់បុគ្គលិកអប់រំ និងអ្នកសិក្សាស្រាវជ្រាវ ដែលមានបំណងចែករំលែកស្នាដៃស្រាវជ្រាវរបស់ខ្លួន ឯកសារបង្រៀន កិច្ចតែងការ ព្រមទាំងឯកសារអប់រំផ្សេងៗទៀត តាមរយៈការដាក់ស្នើឯកសារទាំងអស់ សម្រាប់ផ្តល់ជាប្រយោជន៍ដល់អ្នកប្រើប្រាស់។ ក្រសួងមានក្រុមការងារត្រួតពិនិត្យខ្លឹមសារមាតិកាទាំងអស់នោះមុននឹងផ្សព្វផ្សាយជាសាធារណៈទៅក្នុងគេហទំព័រ។ រាល់ខ្លឹមសារលើគេហទំព័រនេះស្ថិតក្រោមអាជ្ញាប័ណ្ណ Creative Commons Attribution-NonCommercial-ShareAlike 3.0 License (CC BY 3.0) ដែលអនុញ្ញាតឱ្យចម្លង និងចែកចាយបន្ត លើកលែងតែសម្ភារៈដែលស្ថិតក្រោមបញ្ជី "រក្សាសិទ្ធិ"។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា បុគ្គលិកអប់រំ សិស្ស-និស្សិត និងសាធារណជនទាំងអស់ ចូលរួមប្រើប្រាស់គេហទំព័រធនធានអប់រំកម្ពុជា OER Cambodia ឱ្យបានទូលំទូលាយ និងចែករំលែកព័ត៌មានបន្តតាមការគួរ។

ថ្ងៃអង្គារ ១៤រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមីនា ឆ្នាំ២០២២

oer.moeys.gov.kh

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh